ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)

ទីស្នាក់ការកណ្តាលផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 885 745
E-mail: comfrel@online.com.kh Website: http://www.comfrel.org

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

1.លោក ធន សារាយ
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក និងជាប្រធាន ADHOC

2.លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក និងជានាយក CDP

3.លោក យង់ គិមអេង
Mr. YONG Kim Eng
អគ្គលេខាធិការ_នាយកប្រតិបត្តិ PDP-Center

4.លោក យឹម ប៉ូ
Mr. YIM Po នាយករង CPDEW

5.អ្នកស្រី ស៊ុន ចាន់សែន
Mrs. SUN Chansen
ឥស្សរជន_ Dignitary

6.លោក ម៉ាក់ ចំរើន
Mr. MAK Chamroeun
ប្រធាន KYA

7.អ្នកស្រី ប៉ុក បញ្ញាវិចិត្រ
Mrs. POK Panhavichetr
នាយិកាប្រតិបត្តិ CWCC

8.លោក មុំ សារិន
Mr. MOM Sarin
នាយក HRCDO

9.លោកស្រី ពឹង យក់ហៀប
Ms. PEUNG Yok Hiep
ឥស្សរជន_Dignitary

10. លោក គឹម សុវណ្ណ
Mr. KIM Sovann
នាយក VIGILANCE

11.លោក សឺន សែត
Mr. SEN Set
ឥស្សរជន_Dignitary

12. លោក ជាង សុខា
Mr. CHEAMG Sokha
នាយកប្រតិបត្តិ YRDP

ភ្នំពេញថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០១២

# សេចក្តីថ្លែងការណ៍
## ស្តីពី
## ការវាយតម្លៃបរិយាកាសមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ ២០១២

គណៈកម្មាធិការខុមហ្វ្រែល វាយតម្លៃខ្ពស់ចំពោះកិច្ចខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលបានចេញ និងអនុវត្តបទបញ្ជាសេចក្តីណែនាំផ្សេងៗមុនពេលរៀបចំ និងក្នុងពេលឃោសនាបោះឆ្នោត ។ រាជរដ្ឋាភិបាលបានចេញសារាចរពីការផ្អាកមិនឲ្យលក់ដូរ និងពិសារគ្រឿងស្រវឹងមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣នេះ។ ម្យ៉ាងទៀតមានការ ខិតខំរបស់គណៈកម្មាធិការសន្តិសុខសំរាប់ការបោះឆ្នោតក្នុងការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ផងដែរ ។

ខុមហ្វ្រែលបានសង្កេតឃើញថា គណបក្សនយោបាយចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត មានចរិតចាស់ទុំច្រើនក្នុងការដោះស្រាយបញ្ហានានា ហើយបានដាក់បេក្ខជនជាស្ត្រី ដែលមានចំនួន២៥% បើប្រៀបធៀបជាមួយការបោះឆ្នោតឆ្នាំ ២០០៧ ១៦% នៃអ្នកចុះឈ្មោះ ។

យ៉ាងណាមិញ សកម្មភាពនៃការឃោសនាបោះឆ្នោតរវាងគណបក្សកាន់អំណាច និងគណបក្សផ្សេងទៀតមានគំលាតយ៉ាងខ្លាំង ។ គណបក្សប្រជាជនកម្ពុជាបានប្រើប្រាស់ធនធានយ៉ាងសំបូរបែប ដូចជាការដាក់តាំងផ្ទាំងរូបភាពធំៗ នៅតាមដងផ្លូវ រហូតដល់ទៅរៀបចំក្រុមតន្ត្រីនិងកំប្លែងជាច្រើននៅតាមស្រុក/ខ័ណ្ឌ ។ គណបក្សនយោបាយផ្សេងទៀតក៏បានខិតខំធ្វើការឃោសនាបោះឆ្នោតតាមលទ្ធភាពធនធានតិចតួច ក៏ប៉ុន្តែពួកគេជួបឧបសគ្គជាច្រើនរួមទាំងការរារាំង និងខ្វះមធ្យោបាយឃោសនាជាដើម។ ដោយឡែកគណបក្សសមរង្ស៊ីពុំមានការចូលរួមពីមេដឹកនាំបក្សគឺលោកសម រង្ស៊ីក្នុងការគាំទ្រយុទ្ធនាការឃោសនាបោះឆ្នោតឡើយ ។

ការប្រើប្រាស់ធនធានរដ្ឋ ជាពិសេសធនធានមនុស្សជាមន្ត្រីរាជការ នគរបាល និងកងយោធពលខេមរភូមិន្ទមានលក្ខណៈជាប្រព័ន្ធសំរាប់គណបក្សប្រជាជនកម្ពុជា ។

ប្រព័ន្ធផ្សព្វផ្សាយដូចជាទូរទស្សន៍ វិទ្យុ និងកាសែត មិនគោរពច្បាប់ បទបញ្ជា និងនីតិវិធីព្រមទាំងសេចក្តីណែនាំរបស់គ.ជ.ប និងគោលការណ៍វិជ្ជាជីវៈក្នុងកំឡុងឃោសនាបោះឆ្នោត ។ ទូរទស្សន៍ឯកជន ទាំងអស់បានគាំទ្រ និងបន្តលំអៀងផ្សាយគាំទ្រទៅកាន់គណបក្សប្រជាជនកម្ពុជា និងទិះតៀនគណបក្សប្រឆាំងតាំងពីមុនពេលឃោសនាបោះឆ្នោតរហូតដល់ពេលឃោសនាបោះឆ្នោត ។

ក្នុងពេលឃោសនាបោះឆ្នោត ការបំភិតបំភ័យ ភាពមិនប្រក្រតី ការរារាំងសកម្មភាពឃោសនារបស់គណបក្សនយោបាយនានាដែលកើតឡើងទៅលើ សកម្មជនគណបក្សនយោបាយ និងប្រជាពលរដ្ឋ

បើគិតជាចំនួនមធ្យមក្នុងមួយថ្ងៃមានការថយចុះបើ ប្រៀបធៀបនឹងការបោះឆ្នោតមុនៗ (ឆ្នាំ ២០០២ កើតឡើងជាង ១០ករណីក្នុងមួយថ្ងៃ ឆ្នាំ ២០០៧ កើតឡើង ប្រមាណ ៨ ករណីក្នុងមួយថ្ងៃ និងឆ្នាំ ២០១២ នេះ កើតឡើង ប្រមាណ ៦ ករណីក្នុងមួយថ្ងៃ ) ។ ប៉ុន្តែឥទ្ធិពលទាំងនេះនៅពុំទាន់វាស់វែងទំហំបាននៅឡើយទេ ។ ករណីទាំងនោះមានដូចជា ការហែកខិត្តប័ណ្ណ ការទិញសន្លឹកឆ្នោត ការរំខានក្នុងពេលឃោសនា ការទំលាក់ស្លាកគណបក្សនយោបាយ ដែលសរុបប្រមាណជិត ១០០ ករណី ។ ខុមហ្វ្រែលសង្កេតឃើញមានអំពើហិង្សា ២ ករណី ដែលក្នុងនោះ ១ ករណី ក្រុមក្មេងស្ទាវ វាយលើស្ត្រីម្នាក់ជាសកម្មជនគណបក្សសមរង្ស៊ីនៅខេត្តបាត់ដំបង និង ១ ករណីទៀត ស្ត្រីជាភរិយាមន្ត្រីគណបក្សប្រជាជនកម្ពុជាបានវាយដំលើសកម្មជនគណបក្សហ៊្វុនស៊ីនប៉ិច នៅខេត្តបាត់ដំបង ។

ក្រៅពីនេះ ការសង្កេតរកឃើញថា ភាពមិនប្រក្រតីក្នុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនានាដែលបានកើតឡើង ករណីនេះភាគច្រើនគឺនៅខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង ពោធិ៍សាត់ បាត់ដំបង ភ្នំពេញ កំពង់ធំ កំពង់ឆ្នាំង សៀមរាប កំពត កោះកុង បន្ទាយមានជ័យ ស្ទឹងត្រែង ក្រចេះ កណ្តាល ពោធិ៍សាត់ រតនគិរី និងតាកែវ ។ ភាគច្រើននៃអ្នកប្រព្រឹត្តក្នុងករណីខាងលើគឺសកម្មជនគណបក្សប្រជាជនកម្ពុជា និងគណបក្សនយោបាយដែលរងគ្រោះច្រើនពីអំពើទាំងនេះ គឺគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស។

បើទោះបីករណីទិញសន្លឹកឆ្នោត ក្នុងកំឡុងពេលឃោសនាបោះឆ្នោតកើត បានរកឃើញចំនួនប្រមាណ ១០ ករណីក៏ពិតមែន ប៉ុន្តែករណីឲ្យលុយ និងចែកអំណោយមុនថ្ងៃឃោសនាបោះឆ្នោត គឺកើតឡើងនៅស្ទើរគ្រប់ទីកន្លែង ។

យោងតាមរបាយការណ៍ចេញដោយគណកម្មាធិការជាតិរៀបចំការបោះឆ្នោតគិតត្រឹមថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១២ គណកម្មាធិការជាតិរៀបចំការបោះឆ្នោតបានទទួលពាក្យបណ្តឹងជិត ៦០ករណី បើប្រៀបធៀបនឹងឆ្នាំ ២០០៧ ពាក្យបណ្តឹងបានកើនឡើងនៅថ្នាក់ឃុំសង្កាត់ និងថយចុះនៅថ្នាក់ខេត្ត ។ បណ្តឹងភាគច្រើនគឺទាក់ទងទៅនឹងការហែកខិត្តប័ណ្ណ ការរំខានសកម្មភាពពេលឃោសនាបោះឆ្នោត និងការទំលាក់ស្លាកគណបក្សនយោបាយ ហើយបណ្តឹងទាំងនេះច្រើនធ្វើឡើងដោយគណបក្សប្រឆាំងសមរង្ស៊ី ។ ការដោះស្រាយ បណ្តឹងភាគច្រើនគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានពុំពេញចិត្តនឹងការដោះស្រាយរបស់មន្ត្រីដោះស្រាយបណ្តឹង ដោយមូលហេតុមកពីមន្ត្រីនោះសុទ្ធតែមកពីគណបក្សកាន់អំណាច ។

### អនុសាសន៍

- គ.ជ.ប និងក្រសួងមហាផ្ទៃត្រូវខិតខំបន្ថែមការរក្សាសន្តិសុខនៅពេលថ្ងៃស និងថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលធានារយៈពេល "គ្មានអំពើហិង្សា" ។
- គ.ជ.ប និងក្រសួងព័ត៌មាន ត្រូវធានាឲ្យប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ និងឯកជនគោរពនូវគោលការណ៍ និងនីតិវិធី ឬសេចក្តីណែនាំដែលចេញដោយគ.ជ.ប និងក្រសួងព័ត៌មាន និងចាត់វិធានការណ៍ចំពោះប្រព័ន្ធផ្សព្វផ្សាយណាល្មើស ដើម្បីធានាផ្តល់ព័ត៌មានមិនលំអៀង និងដោយមានថ្លឹងថ្លែងឲ្យមានតុល្យភាពក្នុងពេលឃោសនាបោះឆ្នោត ។

- គ.ជ.ប គួរធ្វើការកែប្រែនូវបទបញ្ជា និងនីតិវិធីរបស់ខ្លួនពីអព្យាក្រិត្យភាពមន្ត្រីរាជការពេលឃោសនាបោះឆ្នោត ស្របជាមួយច្បាប់គណបក្សនយោបាយ ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការ ហើយកំណត់អព្យាក្រិត្យភាពដូចជាសមាជិកអង្គការក្រៅរដ្ឋាភិបាលផងដែរ ។

- អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងគ.ជ.ប ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យបញ្ហាដែលអាចកើតឡើង ភាពមិនប្រក្រតីនៅពេលថ្ងៃស ថ្ងៃបោះឆ្នោត (បោះ និងរាប់) ដូចជាការទិញសន្លឹកឆ្នោត ការឃ្លាំមើលរបស់អាជ្ញាធរ និងអ្នកមានអំណាចបំភ័យទៅលើអ្នកបោះឆ្នោត ការបោះឆ្នោតបណ្តាក់ (ដោយមានសន្លឹកឆ្នោត ចេញមកក្រៅការិយាល័យបោះឆ្នោត ) ការរកឈ្មោះមិនឃើញ ការបោះឆ្នោតលើសពីមួយដង (ប្រើប្រាស់ឈ្មោះស្ទួន និងលទ្ធភាពអាចលុបទឹកខ្មៅជ្រះ) ការបដិសេធសិទ្ធិអ្នកបោះឆ្នោត (ដោយមូលហេតុអ្នកបោះឆ្នោតគ្មានប័ណ្ណព័តមាន) ការរាប់សន្លឹកឆ្នោតលឿនបន្លំ និងការបូកសរុបលទ្ធផល ។ល។

- គ.ជ.ប និងក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំឲ្យមេឃុំ គណកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់ក្នុងការបើកចំហរព័តមានស្តីពីការចេញលិខិតបញ្ជាក់អត្តសញ្ញាណដើម្បីបំរើឲ្យការបោះឆ្នោត ដើម្បីឲ្យភ្នាក់ងារគណបក្ស និងអ្នកសង្កេតធ្វើការត្រួតពិនិត្យ ។

ព័ត៌មានបន្ថែមសូមទាក់ទង

លោក ធន សារាយ ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល ទូរស័ព្ទលេខ ០១៦ ៤៤ ០០ ៤៤

លោក សុក សំអឿន អនុប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល ទូរស័ព្ទលេខ ០១២ ៩០ ១១ ៩៩